ឬកពាយ៉ាងដាច់ណាត់ ជាមួយពាក្យចុងក្រោយនៃកិច្ចសន្យាផ្តាច់និស្ស័យ បានបង្ខំឱ្យទ្រូងខាងប្រុសហែងហាងច្រងាប់ច្រងិល សឹងតែមានៈឱ្យនាងស្គាល់ដៃបានបន្ថែមទៀត តែគេទប់ចិត្ត។

«បើគីម៉ាល់មិនធ្វើដៃដល់ មិនបង្ខំចិត្ត ថ្ងៃណាមួយ ហាន់ដាអាចនឹងថើបគីម៉ាល់ដោយខ្លួនឯង!»

គឺសម្តីមួយឃ្លាចាក់ឫសក្នុងជម្រៅចិត្តនេះទេ ដែលប៉ុន្មានពេលមកនេះ គេអាចទប់ចិត្តយ៉ាងល្អចំពោះចរិតផ្លាស់ប្តូររបស់នាង។

«មិនត្រឹមជួបគ្នាទេ! ហាន់ដាត្រូវថើបគីម៉ាល់!»

បុរសវាចាតិចៗ។

បបូរមាត់ដែលរលាស់មួយៗពាក្យខ្លីៗ នាំអារម្មណ៍នាងឱ្យភាន់ភាំង ។

បេះដូងរង្គើព្រឺព្រួច ភ្នែកក្រឡង់ៗទម្លាក់ចុះទៅជាស្រទោស្រទន់ខ្វល់ខ្វាយ ក្តីកង្វល់ជាច្រើនជំពូកបណ្តាក់គ្នាដោយគ្មានមូលហេតុមកសង្កត់ក្នុងផ្ទត់ទ្រូង។

នាងវេភ្នែកចេញហើយបែរខ្នងដាក់គេជាមួយសម្តីតតាំងខ្សោយៗ៖

«ក្នុងយល់សប្តិ!»

«រាល់យល់សប្តផ្អែមៗរបស់អាម្នាក់នេះ នឹងក្លាយជាការពិតនៅពេលព្រឹកឡើង!»

នាងលែងនិយាយខណៈខំទប់មិនបង្ហាញភាពភ័យព្រួយ។ ស្មានាងរង្គើទៅតាមកម្លាំងទប់សម្ពាធផ្លូវចិត្ត ធ្វើឱ្យខាងប្រុសរឹតតែចង់ក្រសោបក្រសាល។ គេនឹកដល់បណ្តាំប្អូនប្រុស។

គ្រប់យ៉ាងហាក់បីដូចជានិស្ស័យ។ ប្រសិននេះជាភព្វវាសនា គេនិងធីតាជាគូបន្តលុះអស់ជីវិត មានអ្វីជាក្តីសុខប្រសើរជាងនេះទៅ?

តែមើលចិត្តខាងស្រីមិនដឹង ស្មានយ៉ាងណាក៏នឹកមិនដល់ជម្រៅអាថ៌កំបាំងក្នុងបេះដូងនាង ចំណែកជុំវិញនាងមានពពួកមនុស្សសៅហ្មងមកលងបន្លាចល្មមឱ្យហួងហែង តើខ្លួននឹងប្រជែងយកស្នេហាពិតពីដើមទ្រូងមនុស្សស្រីដោយវិធីលើកបណ្តាំប្អូនមកបង្ខំនាង ឬក៏ប្រើបេះដូងទៅទិញយកបេះដូង?

ពិតណាស់ គីម៉ាល់គ្មានគម្រោងប្រាប់នាងអំពីពាក្យចុងក្រោយរបស់ពិសិដ្ឋទេ។ គេចង់បាននាងដែលមកក្នុងនាមស្រឡាញ់ មិនមែនមកក្នុងនាមកាតព្វកិច្ចឡើយ។

«សុំទោសរឿងកាលពីក្នុងបន្ទប់!»

គេស្រដីមួយៗហើយបែរខ្នងទៅទិសផ្សេងកាន់បង្កាន់ដៃសម្លឹងដងទន្លេ។ ខាងស្រីមិនវាចាព្រោះនាងកំពុងនឹកឃើញឡើងវិញទាំងក្រហមមុខអាម៉ាស់។

«ពួកនោះមកពីចម្ងាយ ខ្ញុំត្រូវរកវិធី!» គេបន្ថែម។

«វិធីរបស់គីម៉ាល់ គឺយកខ្ញុំទៅជាន់ឈ្លីនៅចំពោះមុខមនុស្សអគតិអស់ទាំងនោះ!»

បុរសគ្រលាស់អណ្ដាតពាសពេញប្រអប់មាត់តែគេមិនតបតទេ។ គេមានពាក្យពេចន៍ច្រើនក៏មិនដឹងផ្ដើមពន្យល់ពីណាទៅណាបាន មានតែនៅស្ងៀមឱ្យនាងជះសំណោក។ នាងមិនដឹងទេថា ជាយូរមកហើយមនុស្សក្នុងគ្រួសារនេះខ្លាចកូនប្រុសច្បងម្នាក់នេះបំផុត។ ប្រសិននាងជារបស់គេហ្មងហែង ពួកនោះថ្លើមប៉ុនណាក៏មិនហ៊ានស្រមៃបង្កបញ្ហាដល់នាងដែរ។ លើកនេះធីតាមានប្រាក់រាប់លានជាមរតកក្នុងដៃ មនុស្សនៅខាងភាគីដែលកំពុងចង់ដណ្ដើម មុខតែមិនព្រមឈប់ផែនការអាក្រក់ៗដោយងាយៗឡើយ ។

សំឡេងនាងលាន់មកបន្ថែម៖

«បើម្នាក់ៗចង់បានលុយអស់ទាំងនោះហើយបើខ្លួនស័ក្ដិសមមែន ប្ដីខ្ញុំប្រគល់វាទៅឱ្យគ្រប់គ្នាហើយមិនមែនខ្ញុំជាអ្នកទទួលទេ!»

ពាក្យ «ប្ដី» ដែលនាងទើបតែ «ហៅ» ពិតជាពីរោះណាស់ ពីរោះដល់ថ្នាក់បុរសម្នាក់នេះកើតក្ដីច្រណែនដោយស្វ័យប្រវត្តិ គឺច្រណែនប្រចណ្ឌសូម្បីជាមួយមនុស្សដែលស្លាប់បាត់ទៅហើយ សូម្បីតែជាមួយប្អូនប្រុសខ្លួនឯងបង្កើត។

បើពិចារណាលើសម្ដីនាងហាក់បីដូច នាងចង់ចាត់បញ្ចូលគេទៅក្នុងចំណោមអ្នកដែលច្រណែនកេរមរតករបស់នាងដែរ?

នាងអាចគិតថា ដែលខ្លួនឱបបង្ខំនាងធ្វើជាគូស្នេហ៍នាងនៅនឹងមុខគេឯងគ្រប់គ្នា ប្រហែលមានបំណងអំពីកេរអស់ទាំងនោះ? នាងមិនដឹងទេថាដែលប្អូនប្រុសប្រគល់នាងមកឱ្យគេនឹងផ្ទេរមរតកឱ្យផងគឺជាចេតនាពិសិដ្ឋក្នុងការប្រគល់អ្វីៗមកឱ្យបងប្រុសម្នាក់នេះដោយឯកឯងរួចទៅហើយទេ?

ខ្ជិលនិយាយច្រើនថែមទាំងគ្មានអារម្មណ៍ពន្យល់ច្រើន គីម៉ាល់ឧទានតិចៗ៖

«ល្ងាចស្អែកជួបគ្នា គង់តែយល់ទេដុកទ័រ!»

ដៃនាងក្ដាប់ទូរសព្ទ តែហាន់ដាមិនហ៊ានខលទេ។

អារម្មណ៍សម្ងាត់បានពន្យល់នាងស្រេចហើយថា គេម្នាក់នៅពីក្រោយខ្នងមិនចូលចិត្តឃើញនាងនិយាយទូរសព្ទពេលនៅជាមួយគេឡើយ។

**ប៉ូលីសជេន**

ទីបំផុតទូកបានចូលដល់កន្លែងដែលត្រូវដល់។ គីម៉ាល់ជួយទម្លាក់ដាក់វ៉ាលិសនាងចុះ។

«អរគុណ»

ដោយវាចាខ្លីៗ ស្រីស្អាតក៏ចាកចេញដោយមិនងាកក្រោយ។

គ្មាននរណាម្នាក់មានសុទិដ្ឋិនិយមចំពោះស្នេហាផ្លេកបន្ទោរមួយ កើតឡើងរវាងបុរសដែលគួរឱ្យទាក់ទាញកាលពីព្រឹក ឥលូវត្រូវជំនួសមកវិញដោយបុរសមានងារជាបងថ្លៃនិងមានចរិតហួងហែង សម្ដីសម្ដៅកាយវិការមិនទៀងទាត់ គួរឱ្យទើសទាល់បែបនេះទេ។

«សង្ឃឹមទៅ ថាបានជួបខ្ញុំទៀតនោះគីម៉ាល់»

នាងគិតបែបនេះពេលជើងឈានឡើងដល់ច្រាំងដីពណ៌មាសនៃតំបន់មេគង្គដ៏ស្រស់ស្រទន់។

ចំណាប់អារម្មណ៍មិនល្អរបស់ តួឯកស្រីដែលធ្លាប់តែស្លូតបូតនិងមិនចេះគិតច្រើន នៅទីបំផុតត្រូវស្ថានការណ៍ចម្លែកៗពេញមួយថ្ងៃមកបង្ខំនាងឱ្យក្លាយជាមនុស្សខ្លាចមុខក្រោយនិងប្រុងប្រយ័ត្នខ្លាំងជាងមុន។

«ជេន!»

នាងស្រែកហៅបុរសវ័យក្មេងសម្បុរសណ្ដែកបាយ កាយសម្បទាខ្ពស់សង្ហាដែលបានរង់ចាំជាស្រេចផ្លូវប្រាបមាត់កំពង់។

នៅក្រចេះនាងមានសុងសក្តិនៅរង់ចាំ លុះដល់មានរឿងធំកើតឡើងនាងត្រូវជ្រុលដំណើរមកដល់ទីនេះទៀត ក៏មានសុភាពបុរសមកចាំទទួលទៀត ។ នាងដឹងថា គីម៉ាល់អាចនឹងកំពុងមើលមកពីលើទូកទាំងមិនសប្បាយចិត្ត តែចិត្តនៅខាងណេះតាំងស្រេចហើយថានឹងមិនងាកក្រោយ ថែមទាំងមិនរវល់ថា គេគិតយ៉ាងណាក៏គិតទៅ។

«អគុណណាស់ជេន!»

នាងនិយាយទាំងញញឹមស្រស់ជាទម្លាប់ធម្មតាដែលគ្រប់គ្នាស្គាល់ហាន់ដា។

ក្រៅពីឱនមកទទួលវ៉ាលិស សុភាពបុរសជេនឆ្លៀតខ្សឹបសួរះ

«មានរឿងអី? ឃើញ SMS ខ្ញុំប្រញាប់មកភ្លាម!»

នាងទម្លាក់ទឹកមុខហើយដកដង្ហើមធំ។

បុរសនេះយល់ការណ៍ក៏និយាយតឿន៖

«ឡើងឡានសិនមកអ៊ុំចឹង!»

នាងងក់ក្បាលបន្តដំណើរកាត់តាមសួនឆ្ពោះទៅរកជំនិះដែលនៅថ្នល់ម្ខាង។

«ហើយចុះជិះទូកអ្នកណាមក! ទូកខាងគ្រួសារប្ដីហ្មែន?»

គេមិនដឹងថា ពេលនេះសូម្បីតែនាងចង់រកចម្លើយត្រឹមត្រូវមួយមកឆ្លើយក៏ពិបាកផង។ ដំបូងនាងចង់ប្រាប់ថា មិនមែនទេ តែមិនដឹងម៉េចនាងនៅស្ងាត់វិញល្អជាង ព្រោះគីម៉ាល់មិនមែនជាគ្រួសារប្ដីខ្លួន តើជាអ្នកណាវិញ?

«ប្រញាប់ទៅជេន! ឃ្លានណាស់ណ៎ា! ពីព្រឹកទល់ឥឡូវគ្មានអីទ្រាប់ពោះទេ!»

ជេនសម្លឹងនាងពីលើដល់ក្រោម ជំនួសចម្លើយ។ គេងាកក្បាលឱ្យសញ្ញាហាន់ដាឡើងឡាន៖

«ឡើងមក!»

គេចុចបើកទ្វាររួចដើរហួសទៅខាងក្រោយដាក់វ៉ាលិសចូល។

នារីមកដល់ទីដែលនាងយល់ថាមានសុវត្ថិភាព ក៏បិទភ្នែកសន្សឹមៗផ្ដេកក្បាលនឹងបង្អែកកៅអី សាកល្បងបំភ្លេចទុក្ខព្រួយមួយខណៈ។

ប៉ុកៗ

ស្នូរគោះកញ្ចក់ពីចំហៀងខាងស្ដាំ......

ហាន់ដាបើកភ្នែកព្រឹមៗឡើងមកវិញ ទាំងគិតថាខ្លួនច្រឡំដៃចុចសោបិទមិនឱ្យជេនចូលមកកន្លែងអង្គុយបាន។ មួយត្របកភ្នែកបង្ហើបដំបូងនាងឃើញសន្លឹកស្រទាប់ផ្កាកុលាប ហើយបន្ទាប់មកមុខមាត់ស្រស់សង្ហានៃនៅបុរសម្ចាស់ទូកនៅពីក្រោយបាច់ផ្កា។

ស្រស់ស្រីភ្ញាក់ដូចកន្ត្រាក់......

ដោយងើបអង្គុយត្រង់ខ្លួនភ្លាមៗ ទន្ទឹមនឹងចាប់អារម្មណ៍ថា ជេនក៏បានចូលមកដល់ទីអង្គុយខាងឆ្វេងដៃខ្លួនដែរហើយ ដូច្នេះភាពភ័យខ្លាចដែលថាគីម៉ាល់អាចនឹងសម្លុតនាងបានបន្តដូចមុន ទៅមិនរួចទេ។

«អ្នកណាហ្នឹង?»

ជេនសួរតិចៗឯភ្នែកសម្លឹងទៅទិសដៅក្រៅកញ្ចក់ចំហៀង នាយហាក់ច្រណែននឹងរូបរាងអ្នកខាងក្រៅនោះ។

នារីចុចកញ្ចក់ចុះយឺតៗ តាមថានាងមិនចង់ទេ តែនាងភ្លេចផ្កាហើយនាងគួរតែទទួលយកមកឱ្យឆាប់បានចប់។

«ប្រញាប់ម្ល៉េះ ភ្លេចនេះភ្លេចនោះ!»

សំឡេងគេបន្ទោសលាយស្នាមញញឹមសម្លឹងមកកាន់វង់ភក្ត្រតូចច្រឡឹងដែលមិនបានត្រៀមចិត្តច្បាស់លាស់ក្នុងការសម្លឹងមករកនាយតបវិញឡើយ។

នាងលូកដៃទាំងពីរទទួលយក ជាមួយវាចាខ្សោយៗ៖

«អរគុណ!»

«អត់ឮ!»

គេនិយាយឌឺដងជាមួយកែវភ្នែកអណ្ដែតអណ្ដូងធ្វើហាក់បីដូចជានៅទីនេះ គ្មានវត្តមានអ្នកណាក្រៅតែពីនាងហើយនឹងគេ។ ស្នាមថើបច្រងាប់ច្រងិលនៅពេលមិនដល់ពីរម៉ោងមុននេះមិនទាន់បានទម្លាក់ទម្ងន់ទុក្ខព្រួយចេញពីបេះដូងខាងស្រីនៅឡើយផង ពេលនេះគេមកបង្ហាញខ្លួនចំៗ ដោយប្រកាន់ឫកពាយ៉ាប់ៗនៅនឹងមុខញាតិមិត្តនាងទៀត មិនឱ្យនាងចាប់ផ្ដើមស្លន់ចិត្ត?

ស្រីស្អាតងើបមុខសម្លឹងបុរស ជាមួយពន្លឺភ្នែកចង់អង្វរឱ្យគេចេះមើលកាលៈទេសៈផង ដឹងអីគេធ្វើមិនដឹងមិនឮនឹងការព្រមានរបស់នាងថែមទាំងមិនព្រមចាកចេញទៅណា។

ត្បិតតែឃើញថា នាងមិនសូវរាក់ទាក់ពេញចិត្តមនុស្សនៅក្រៅកញ្ចក់ តែជេនមិនដឹងរឿងអ្វីលើសពីនេះឡើយ។

គេលូកដៃទៅរាក់ទាក់ជាការគួរសម៖

«ខ្ញុំជេន! ពួកម៉ាកហាន់ដា!»

គីម៉ាល់តាមថាមិនរវល់ជាមួយជេនទេ តែពាក្យថា «ពួកម៉ាក់» គឺហាក់សែនទើសណាសសម្រាប់ត្រចៀកគេ។ បុរសងើបមុខសម្លឹងគូសន្ទនា ទាំងព្រងើយនឹងដៃដែលគេបោះមក ចំណែកទឹកមុខរឹតតែបង្ហាញថា គេគ្មានថ្ងៃចាប់ដៃជេនទេ។

ហាន់ដាតឹងទ្រូង......

នេះហើយសុភាពបុរសរបស់ឯង នាងហាន់ដា! ស្រីស្អាតគិតទាំងក្រញូវៗ ។

គីម៉ាល់មិនបានចប់ត្រឹមឫកពាប៉ុណ្ណឹងទេ។ ភ្នែកទាំងគូដ៏មុតថ្លារបស់គេបញ្ចេញសញ្ញាសំញើញទៅខាងប្រុសហើយសម្តីហួងហែងខាងស្រីក៏ចាប់ផ្តើមតំណាលគ្នាដែរ៖

«អត់មានអ្នកផ្ទះមកទទួលទេ?!»

«ជេននេះជាអ្នកផ្ទះ ជាមិត្ត ជាមនុស្សដែលខ្ញុំទុកចិត្តបានគ្រប់ពេលគីម៉ាល់!»

នាងថាញាប់ស្មេព្រោះ ក្រោយពី «ទប់» គឺមនុស្សយើងត្រូវ «ផ្លាយ»។ នាងដឹងថាគេខឹង ចំណែកខាងជេនបង្អើបស្មាបានចិត្តណាស់ ក្រោយពីទម្លាក់ដៃដែលត្រូវបានបដិសេធមកវិញមិនទាន់អីផងត្រូវបានខាងស្រីចេញមុខសងសឹកឱ្យភ្លាមៗ។

ហាន់ដាមិនមើលមុខគេទេ ព្រោះមិនចង់ឃើញសភាពរបស់មនុស្សចរិតហួងហែង។ នាងនិយាយបន្ថែមពីរោះពិសា៖

«ខ្ញុំទៅបានហើយមែនអត់គីម៉ាល់?!»

បុរសញញឹមថយតិចៗ ។

នាងឃើញតាមកញ្ចក់សម្រាប់សម្លឹងចំហៀង ខាងជេនទៅវិញទេ។

ជេនបានដៃហើយពេលនេះ។ គេចុចបិទកញ្ចក់ហើយញាក់ចិញ្ចើមស៊ីញ៉ូលាគីម៉ាល់មួយទៀតជារង្វាន់បេះដូង មុនពេលរ៉ឺយែរឡានថយក្រោយ និងបោលក្តួងចេញបញ្ចោះបន្សោកយ៉ាងសង្ហា។

«ឫកពារអស្ចារ្យ!»

ជេនរអ៊ូតិចៗទាំងគ្នាន់ក្នាញ់។

តាមចរិតជេនប្រសិនមិនមានសុភាពនារីនៅក្បែរម្ល៉េះសម គេអាចនឹងកៀរអ្នកឈរក្បែរឡានហ្នឹងឱ្យធ្លាក់ជង្ហុកស្គាល់ពណ៌ទឹកភក់ដក់ខែវស្សាលើដីស្ទឹងត្រែងម្តងហើយ ទើបសមនឹងចរិតរបស់គេដែលធ្វើដាក់ខ្លួនមុននេះ។ ទោះយ៉ាងណាគេមិនចង់ឱ្យនារីបន្ថែមអារម្មណ៍ទោមនស្ស បានជានិយាយពេបជ្រាយត្រឹមប៉ុន្មានម៉ាត់ខ្លីក៏នឹកឃើញឈប់និយាយវិញហើយងាកមកសម្លឹងអាការៈមិត្តភក្តិម្តង។

«អ្នកណាគេមិញ? ហើយផ្កានេះគេជូនហាន់ដាឬម៉េច?!»

អ្នកសួររវេភ្នែកសម្លឹងបាច់ផ្កាដែលនារីឱបក្នុងដៃ។ ដោយចៃដន់មួយក្រឡេកភ្នែក គេសម្លឹងហួសទៅឃើញអ្វីមួយក្នុងកអាវនាង។

ជេនគិតដល់រឿងមួយធ្វើឱ្យផ្ទៃមុខក្រហមដោយការអៀនអន់។

បុរសងាកមុខចេញធ្វើឱ្យនារីហាក់ដឹងខ្លួន។ នាងឈ្ងោកឃើតៗសម្លឹងកអាវខ្លួនឯង។នៅលើដើមទ្រូងហ្មត់រលោង នៅបន្សល់ខ្សែដៃអំបោះមួយពណ៌គគីរ។

ប្រាកដណាស់ នេះមិនមែនរបស់នាងទេ។ បុរសចរិតយ៉ាប់ម្នាក់នោះ បានប្រតាយបង្ខំនាងកាលពីក្នុងទូកហើយបន្សល់វត្ថុអនុស្សាវរីយ៍ពីកដៃគេមកទើរទីនេះ។
អាម៉ាស់!

នាងប្រាប់ខ្លួនឯងស្ងាត់ៗ។

អ្នកណាក៏មើលដឹងថា នេះជាខ្សែដៃរបស់មនុស្សប្រុសដែរ។ ទោះបីជេនមិននិយាយ មិនសួរ ក៏មិនដឹងគេកំពុងគិតពីនាងអ្វីខ្លះ យ៉ាងណាខ្លះនោះដែរ។

«ខ្សែដៃទុកឱ្យល្អផង! បង្កាពេលនឹកគ្នា អាចជួយបានខ្លះ!»

នេះជាសារដែលលោតមកលើអេក្រង់របស់នាង។

ស្រីស្អាតស្ទុះទទួលមកអានទាំងបើកភ្នែកមូលក្រឡង់។ ហាន់ដាក្តុកក្តួលក្នុងទ្រូងថែមទ្វេ។

មនុស្សនោះសូម្បីលេខទូរសព្ទរបស់នាងក៏គេមានដែរ? គេជាខ្មោចឬជាបិសាចឱ្យប្រាកដទៅ?

មកក្បែរគ្នាប៉ុណ្ណឹង គេឃើញខ្សែដៃគេទើរលើទ្រូងយើងទៀត? អ៊ីចឹងសោះបានជា ថាឱ្យយ៉ាងញាប់គេមិនកើតខឹងបែរជាញញឹម?

នាងបែរឃើតៗ រកសម្លឹងស្រមោលគេពីក្រោយឡាន។

រថយន្តបោលចេញឆ្ងាយហើយតាមកម្លាំងចិត្តអ្នកបើកទៅហើយ។ ជេនចាកចេញមករហ័សព្រោះមិនសូវសប្បាយចិត្តចំពោះវត្តមានគីម៉ាល់ ដូច្នេះនាងមិនអាចឃើញម្ចាស់ខ្សែដៃទៀតបានទេ មានតែ SMS របស់គេដែលបន្សល់ទុកឱ្យ។

«ជេន! លែងចង់ញ៉ាំអីហើយ ខ្ញុំចង់ទៅម៉ាក់ឥឡូវនេះ!»

បុរសដៀងមើលនាងគេព្រិចភ្នែក៖

«អូខេ! »គេឆ្លើយស្រាលៗ។

នាងឱនសម្លឹងបុស្បាក្នុងដៃ ដោយនិយាយបន្តៈ

«ផ្កានេះ មិនមែនរបស់ម្នាក់ហ្នឹងទេ! ខ្ញុំទិញមកជូនម៉ាក់!»

«អូខេ!»

ជេននិយាយខ្លីៗទៀត តែចិត្តនាងវិញគិតវែងឆ្ងាយ។ ចាប់តាំងពីពិសិដ្ឋស្លាប់ទៅ នាងគិតដល់អនាគតខ្លួននិងរឿងបេះដូង។

ពិតណាស់មង្គលការជាមួយពិសិដ្ឋមិនមែនជាអ្វីដែលបេះដូងចង់បានទេ ហើយមនុស្សដែលនាងស្រឡាញ់ពិតក៏មិនមែនគេ រឹតតែមិនដឹងថាជាអ្នកណា។ នាងគ្មានម្ចាស់បេះដូងទេ។ រហូតដល់ពេលដែលស្វាមីកាតព្វកិច្ចស្លាប់ទៀតសោត នាងនៅតែនឹកមិនឃើញថាចង់រស់នៅជាមួយអ្នកណាដើម្បីកំដរជីវិតដែលនៅសល់ ប៉ុន្តែគ្រប់យ៉ាងហាក់ស្រអាប់ទៅៗ មិនច្បាស់លាស់ ដូចគ្នានឹងបេះដូងដែលសាបឈឹងគ្មានរសជាតិមួយនេះ។

## ខាងប្រុសហៅនាងថា «ប្អូនថ្លៃជើងល្អ»

«ឈ្មោះជេន ធ្វើការនៅផ្នែកព្រហ្មទណ្ឌខេត្ត ធ្លាប់ផ្លាស់ទៅភ្នំពេញ៦ខែទើបវិលមកវិញបានមួយបីអាទិត្យ! ពាក់សក្តិ៥ រៀនចប់បរិញ្ញាវិទ្យាសាស្ត្រនយោបាយនៅបាងកក! ចេះភាសាខ្មែរ អង់គ្លេស ថៃ ឡាវ ស្ទាត់ជំនាញ ជាកូនខ្មែរអ្នកស្រុកសៀមប៉ាង ឪពុកជាប៉ូលីសចូលនិវត្ត ម្តាយជាអយ្យការចូលនិវត្តដូចគ្នា មានប្អូនស្រីម្នាក់អាយុ២១ឆ្នាំរៀនច្បាប់នៅភ្នំពេញ ជាគ្រួសារធូរធារតាំងពីជំនាន់ជីទួតជីលួតជីលាមក។

Kemal អង្គុយបែរខ្នងស្តាប់ តែកែវភ្នែកផ្ចង់ជាប់លើទំព័រហ្វេសប៊ុកនាង។ ពិសិដ្ឋហាន់ដា ឈ្មោះនាងដាក់លើប្រូហ្វាល់ គេទន្ទេញចុះឡើងក្នុងបេះដូង មុនពេលលើកម្រាមឆ្វេងច្បូតមុខ បំភ្លៃចោលអារម្មណ៍ច្រណែន។

កូនចិត្តល្អួចលាក់តូចមួយ «ពិស័កហាន់ដា» ទំនងជាង! គឺលេចឡើងក្នុងចិត្តសម្ងាត់ដូចឆ្កួតៗ តែជាភាពឆ្កួតដែលលងបន្លាចបុរសយើងពេញមួយជីវិតមកហើយ។

មែនហើយ! គេទទួលស្គាល់ថាខ្លួនឯង មានចំណុចខ្សោយធំៗ២ក្នុងជីវិតនេះ ដែលចងជាប់សណ្តោងក្បែរទ្រូងដកមិនចេញកែមិនបាននោះគឺ ចិត្តច្រណែន ពិសេសសម្រាប់មនុស្សស្រីដែលគេស្រឡាញ់និងមានចំនួនតិចបំផុតក្នុងជីវិតនេះ បន្ទាប់ពីគេបាត់បង់ម្តាយគេទៅ។

«បងគឺម៉ាល់!»

វុធខ្សឹបតិចៗ ធ្វើឱ្យបុរសប្រញាប់ចុចបិទទូរសព្ទហើយងាកទៅសម្លឹង។

«នៅនេះមានក្លឹបឡូយមួយឈ្មោះ Night Sweet ខ្ញុំស៊ើបរួចហើយ ខ្មែរក៏មានឡាវក៏មានវៀតណាមក៏មាន ស្អាតៗភ្លឹងបង!»

បុរសនេះទម្លាក់ភ្នែកសម្លឹងកម្រាលឈើក្រហមក្រម៉ៅរលោងស្រិលក្រោមប្រអប់ជើង។ ឆាកជីវិតដែលរួមរឹតដោយស្រមោលពេស្យា ស្នេហាដោះដូរ គ្រប់ពណ៌គ្រប់រសជាតិរបស់គេបានក្លាយជារឿងធម្មតាសម្រាប់មនុស្សជំនិតនានាទៅហើយ។ កម្រមានរាត្រីណាមួយដែលគេអាចឆ្លងកាត់បានដោយគ្មានមនុស្សស្រីណាស់។ ហើយនេះជាចំណុចខ្សោយធំទីពីររបស់គេ។

យប់នេះសម្រាក!

បុរសឆ្លើយខ្លី ឯវុធមីងមាំង។ អ៊ុននិងវុធជាដៃឆ្វេងស្តាំ តែវុធជាមនុស្សមានចរិត «ចូលចិត្តស្រីៗ» ដូចនាយចៅហ្វាយបេះបិទ បានជាគេតែងតែមិនធ្វើឱ្យមានចន្លោះប្រហោងក្នុងការស៊ើបដំណឹងផ្ទះរកបណ្តាស្នេហ៍ថ្មីៗទេ រាល់ពេលធ្វើដំណើរទៅណាក្តី។ នេះជាលើកទីមួយដែលគេឮពាក្យ «បដិសេធ» តុអាហារឈ្ងុយៗថ្មីៗចេញពីមាត់គីម៉ាល់។

«ដេកពួនបានហើយអ្ហា!»

អ៊ុនឱីដងឱ្យគេមុនពេលងាកមកឱនខ្សឹបប្រាប់គីម៉ាល់៖

«បង! ខាងពូយឹមមកដល់ចាំនៅខាងក្រៅ ថាចង់អញ្ជើញបងគីម៉ាល់សាកងៀតឈ្លូស!»

គេមិនរវល់បែរជាងើបមុខសួរស្រាលៗ៖

«ហាន់ដានៅផ្ទះជាមួយអាម្នាក់ប៉ូលីសហ្នឹង?!»

អ៊ុនគ្រវីក្បាលតិចៗចំពោះកែវភ្នែកមុតថ្លានៃចៅហ្វាយសង្ហា។ ភាពព្រួយកង្វល់ក្នុងភ្នែកគីម៉ាល់ដែលសម្លឹងមកម៉ក់ៗរង់ចាំចម្លើយហាក់បីដូចជាប្រាប់អ៊ុនជាសម្ងាត់ថាបេះដូងគេជោគជាំទៅដោយនារីម្នាក់នោះ គ្មានថ្នាំកែឡើងទេ។

«អត់ទេ នៅក្បែរគ្នាបង! ហាន់ដាមានផ្ទះថ្មក្រោមលើឈើ ចំណែកផ្ទែកផ្ទះម្នាក់ហ្នឹងជាផ្ទះកិងបុរាណសសរបេងនាងនួនល្បីខាងទេសចរណ៍ខេត្តគេឧស្សាហ៍មកធ្វើកម្មវិធីណាស់! ផ្ទះពីរហ្នឹងជាប់របងគ្នាមានផ្លូវចេញចូលរកគ្នាបានតាមរបងចំហៀងទៀត»

ប្រុសស្អាតសើចចុងមាត់តិចៗជាសញ្ញាខឹងក្នាញ់។ សម្តីនាងនៅសៀតជាប់បេះដូងនាយ៖

«ជេននេះជាអ្នកផ្ទះ ជាមិត្ត ជាមនុស្សដែលខ្ញុំទុកចិត្តបានគ្រប់ពេលគីម៉ាល់!»

«ពីរនាក់នេះស្គាល់គ្នាតាំងពីក្មេងមក! រៀនជាមួយគ្នា ញ៉ាំបាយជាមួយគ្នា! ឮមកថា ម្ដាយរបស់ហាន់ដាកាលពីក្មេងក៏ធ្លាប់មកផ្ញើខ្លួន ធ្លាប់ស្នាក់នៅហូបបាយរៀនសូត្រជាមួយម្ដាយជេនកាលពីនៅក្មេងៗ គឺជ្រកកោនផ្ទះជីតារបស់ឈ្មោះជេន!»

គេងើបមុខសួរអ៊ុនភ្លាម៖

«ម្ដាយហាន់ដាមិនមែនអ្នកនៅស្រុកនេះទេ?!»

«ឮថាអ្នកកោះបង! គេមានផ្ទះនៅកោះមួយទៀត តែមិនដឹងកោះអីកំពុងស៊ើប!»

«នៅស្ទឹងត្រែងនេះមានកោះប៉ុន្មាន?!»

«ច្រើនបង! គេថាមានផ្លូវការ មានក្រៅផ្លូវការ! កោះខ្លះតូចៗពេក មានមនុស្សនៅតែមួយគ្រួសារពីរប៉ុណ្ណឹងបង!»

«អ៊ុន មានមើលយាមកាមក្រែងពួកផ្ទះភ្នំពេញមកឆាឆៅគេនិងគ្រួសារដែរ?!»

«ដាក់មនុស្សឃ្លាំការពារម្ដេចប្អូនម៉ោងបង! តែខាងប៉ូលិសនោះក៏គេប្រយ័ត្នដែរ!»

បុរសដកភ្នែកចេញពីមនុស្សជំនិតទាំងស្ងួតស្ងប់។

គេជិតដិតគ្នា ដល់ថ្នាក់សូម្បីរឿងក្រុមពូឃឹមមកដល់ទីនេះគម្រាមសុវត្ថិភាពគេ ក៏និយាយប្រាប់អាជេនម្នាក់ហ្នឹងដែរ? ដល់ហើយប្អូនថ្លៃជើងល្អ!

គីម៉ាល់លើកដៃជូតមាត់គិតទាំងសៅហ្មង។ អ៊ុនដឹងថា យប់នេះនឹងមានអ្នកខ្លះអង្គុយសម្លឹងទន្លេសេកុងទល់ភ្លឺមិនខាន បើមើលតាមបន្ទុកកង្វល់ក្នុងទ្រូងសម្ងាត់របស់គេ។

អ៊ុនឆ្លៀតនិយាយតិចៗ៖

«បើបងគីម៉ាល់មិនទាន់សម្រាន្តដដែល ហូបពីរបីកែវជាមួយពូឃឹមសិនឬម៉េច?!»

បុរសជ្រួញចិញ្ចើម។ ពូឃឹមជាពូបង្កើតនៃជំទាវនារីភា ដែលជាម្ដាយចុងក្មេងខ្ជិរបស់ខ្លួន ។ ក្រុមនេះក្រៅពីតាមគម្រាមយាយីហាន់ដាដល់ដែនទន្លេជាស្រុកកំណើតនាង ថែមទាំងលើកគ្នាមករកនាយទាំងយប់ តើគេមានគម្រោងការល្អពីណាមកនោះ។

«ដេញចេញទៅ! ហើយបើថាមានរឿងសំខាន់ណាស់ ឯងទៅស្ដាប់ ទៅតែចុះ! ទៅស្ដាប់នៅក្រៅរបងកុំទទួលពួកអស់នេះឱ្យឡើងផ្ទះ! រកទុកចិត្តមិនបានទេ!»

បុរសឆ្លើយខ្លីៗឆាប់ចប់នឹងអាលឱនមកពិនិត្យហ្វេសប៊ុកបន្ត។

ចប់! គេរកនាងលែងឃើញហើយ!

មិនបានប៉ុន្មាននាទីសោះ នាងលុបចោលគណនេយ្យហ្វេសប៊ុកតែម្តងឬយ៉ាងណា?

គេស្វែងរកនាងចុះឡើងតែរក យ៉ាងណាក៏រកមិនឃើញដែរ។

ហាន់ដាអើយហាន់ដា! គេហៅឈ្មោះនាងតិចៗក្នុងបេះដូងជាមួយស្នាមសំណើចតែម្នាក់ឯង។

«យើងស្មានថា គេចអាគីម៉ាល់រួចហ្មែន? យើងកំពុងនឹកអាម្នាក់នេះដែរឬម៉េច?!»

ក្រោមជំនោរដងទន្លេត្រសៀកត្រសុំ នារីឈរកាន់ទូរសព្ទម្នាក់ឯង ទាំងពិភាល់មិនស្ងប់ក្នុងចិត្ត។ មិនមែនថា ចង់បំភ្លេចបុរសម្នាក់នោះពីក្នុងចិត្ត ក៏អាចធ្វើបានភ្លាមៗ ដូចការលុបចោលគណនេយ្យហ្វេសប៊ុកអ៊ីចឹងនោះទេ។

វាំងននលើរានហាលមុខបន្ទប់បោករវិចតាមកម្លាំងព្រះវាយោ ហាក់រំឭកបន្ថែមព្រឹត្តិការណ៍សឹងលោះព្រលឹងកាលពីថ្ងៃចូលមកក្នុងមណ្ឌលចងចាំនៃនារីរូបល្អ។ នាងនឹកឃើញជានិច្ចពេញមួយល្ងាចនេះដល់ស្ថានភាពដែលមនុស្សសម្រុកឡើងទូក ខណៈគេជ្រែងជើងវាំងទ្វារដែកជាប់ម៉ឺងហើយក៏ ដោះអាវខ្លួនគេ ចេញនិង លូកខ្វាកទៅទាញរហែកវាំងនន លើបង្អួច រុំនាងនឹងគេត្រសុលចូលគ្នា ក្នុងសំណុំវាំងននតែមួយ បំភាន់ធ្វើហាក់បីដូចជាខ្លួនប្រាណទាំងទ្វេ អាក្រាតជាមួយគ្នាដូច្នោះដែរ ។

ស្រីស្រស់ផ្ទេចភ្នែកព្រោះចំហាយអៀនខ្មាសនៅមិនទាន់រសាយបាន...